ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ៤០១ រថ.អគរ.ប្រក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារពង្រឹងយន្តការប្រមូលចំណូលធនធានរ៉ែ

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែដោយសម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់
- បានឃើញសេចក្តីសម្រេចលេខ ០០៩៦ រថ.អកទទ.សសរ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការចាត់តាំងថ្នាក់ដឹកនាំដើម្បីទទួលខុសត្រូវក្នុងការតាមដាន ការកត់ត្រា ការកៀរគរចំណូល និងចាត់វិធានការទារបំណុល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារពង្រឹងយន្តការប្រមូលចំណូលធនធានរ៉ែរបស់ក្រសួងរ៉ែនិងថាមពល ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉េង សក្តិធារ៉ា | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម ហូ វិចិត្រ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម ប៉េង ណារុធ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម ញ៉ឹក សុមេធ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥- ឯកឧត្តម យស មុនីរ៉ាត់ | អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ | អនុប្រធាន |
| ៦- លោកស្រី យ៉ែម កាន់នីកា | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៧- លោក ផៃ លីឌីន | អគ្គនាយករងនៃអគ្គនាយកដ្ឋានធនធានរ៉ែ | សមាជិក |
| ៨- លោក ហ៊ីង ទន់ | ប្រធាននាយកដ្ឋានរ៉ែសំណង់ | សមាជិក |
| ៩- លោក មុយ ងួន | អគ្គាធិការរង | សមាជិក |
| ១០- លោក នួន នរិន្ទ | ប្រធាននាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ១១- លោក ហុង បុណា | អនុប្រធាននាយកដ្ឋានរ៉ែសំណង់ | សមាជិក |
| ១២- លោក យិន រដ្ឋា | អនុប្រធាននាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ១៣- លោកស្រី បុទ្ធិ វិជ្ជនី | ប្រធានការិយាល័យនៃនាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានរ៉ែ | សមាជិក |
| ១៤- លោក ហ៊ល យូហ៊ួត | ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៥- លោក ហៃ គឹមលាំង | មន្ត្រីនៃនាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ១៦- លោក ហឿន ស៊ាងឡេង | មន្ត្រីនៃនាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ១៧- លោក មាស ដារ៉េត | មន្ត្រីនៃនាយកដ្ឋានអាជីវកម្មរ៉ែ | សមាជិក |
| ១៨- លោកស្រី អ៊ឹង គីមមុយលី | មន្ត្រីនៃនាយកដ្ឋានជំរុញនិងអភិវឌ្ឍន៍ធនធានរ៉ែ | សមាជិក |
| ១៩- កញ្ញា សយ សីហមុនា | មន្ត្រីនៃនាយកដ្ឋានជំរុញនិងអភិវឌ្ឍន៍ធនធានរ៉ែ | សមាជិក |
| ២០- លោក តាំង ប៊ុនហុង | ជំនួយការឯកឧត្តមម៉េង សក្តិធារ៉ា | សមាជិក |

**ប្រការ២ .-**

ក្រុមការងារខាងលើមានភារកិច្ចដូចតទៅៈ

- ពង្រឹងសមត្ថភាពស្ថាប័នកិច្ចរបស់មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដើម្បីគ្រប់គ្រងនិងប្រមូលចំណូលធនធានរ៉ែ

- ត្រួតពិនិត្យនិងអធិការកិច្ចលើការងារប្រមូលចំណូលធនធានរ៉ែតាមបណ្តារាជធានី ខេត្ត
- ចុះពង្រឹងការអនុវត្តប្រកាសអន្តរក្រសួងលេខ ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ
- ចុះពង្រឹងការអនុវត្តប្រកាសលេខ ០០៩៣ រថ.រស.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីស្វ័យប្រកាស និងបង់សួយសារលើតម្លៃធនធានរ៉ែដោយសម្បទានិកដែលមានអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់
- ពិនិត្យនិងលើកស្នើវិធានការចាំបាច់នានា ដើម្បីធានានូវប្រសិទ្ធភាពក្នុងការតាមដានការកត់ត្រា ការកៀរគរចំណូលធនធានរ៉ែ និងការចាត់វិធានការតឹងទារបំណុល។

**ប្រការ៣ .-**

ក្រុមការងារពង្រឹងយន្តការប្រមូលចំណូលធនធានរ៉ែ មានសិទ្ធិប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានជំនាញបន្ថែមតាមការចាំបាច់។

**ប្រការ៤ .-**

សេចក្តីសម្រេចលេខ០១៥៦រថ.អធរ.សសរ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារពង្រឹងយន្តការប្រមូលសួយសារធនធានរ៉ែតាមបណ្តារាជធានី ខេត្ត និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត និងសាមីជនដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ